# ការអធិស្ឋាន



ការអធិស្ឋានសំខាន់ខ្លាំងណាស់សម្រាប់គ្រិស្តបរិស័ទ ប្រៀបបីដូចជាអុកស៊ីសែនសម្រាប់រាងកាយទាំងមូលយ៉ាងដូច្នោះដែរ។ ការអធិស្ឋាន គឺជាទំនាក់ទំនងរវាងយើង និងព្រះជាម្ចាស់ ដោយមានការឆ្លើយឆ្លងគ្នា។ ការអធិស្ឋាន ជាការជម្រុញ ឲ្យមានកម្លាំង និងឫទ្ធអំណាចយ៉ាងសម្បើមនៅក្នុងជីវិតរបស់យើង និងអ្នកដ៏ទៃ។ ជាលទ្ធផល ការអធិស្ឋានអាចមានការប៉ះពាល់ដល់ ព្រលឹងវិញ្ញាណ រូបកាយ គំនិតស្មារតី និង ភារៈសំខាន់ផ្សេងៗទៀតរបស់មនុស្ស ។

*«ចូរអធិស្ឋានដោយព្រះវិញ្ញាណគ្រប់ពេលវេលា ដោយពាក្យអធិស្ឋាន និងពាក្យទូលអង្វរគ្រប់យ៉ាង ហើយចាំយាមក្នុងសេចក្តីនោះឯង ដោយគ្រប់ទាំងសេចក្តីខ្ជាប់ខ្ជួន និងសេចក្តីទូលអង្វរឲ្យពួកបរិសុទ្ធទាំងអស់។» អេភេសូ ៦:១៨*

ព្រះយេស៊ូវពឹងផ្អែកលើព្រះវរបិតារបស់ព្រះអង្គក្នុងគ្រប់កិច្ចការទាំងអស់ដែលទ្រង់ត្រូវសម្រេច ហើយយើងក៏ត្រូវធ្វើយ៉ាងដូច្នោះដែរ ។ សូមបំពេញទីកន្លែង និងពេលវេលាក្នុងថ្ងៃដែលព្រះយេស៊ូបានអធិស្ឋានៈ

| **ទីកន្លែង** | **ពេលវេលាក្នុងថ្ងៃ** |
|---|---|
| ម៉ាកុស ១:៣៥ ________________ | ម៉ាកុស ១:៣៥ ____________________ |
| ម៉ាកុស ៦:៤៦ ________________ | លូកា ៦:១២ ______________________ |



លូកា ៥:១៦ __________________ លូកា ២២:៤៥ ____________________

ជួនកាលនៅពេលដែលខ្ញុំមានអារម្មណ៍ថាសោះកក្រោះខាងវិញ្ញាណ គឺដោយសារតែខ្ញុំមិនបានចំណាយពេលនៅក្នុងការអធិស្ឋាន ប្រហែលជាធ្វើបានត្រឹមតែពីរបីនាទី ក្នុងមួយថ្ងៃប៉ុណ្ណោះ ។ ដូច្នេះហើយ ដោយមានមនសិកាមុះមុត ខ្ញុំបានខំព្យាយាម និង អធិស្ឋានឱ្យបានយូរជាងនេះ។

ព្រះគម្ពីរបង្ហាញយ៉ាងច្បាស់ថា គួរតែមានកំណត់ពេលវេលាជាក់លាក់ណាមួយសម្រាប់ការអធិស្ឋាន ជាមួយនឹងចិត្តខ្ជាប់ខ្ជួនដោយផ្តោតទៅរកព្រះវរបិតា ដោយអាកប្បកិរិយានៃការអធិស្ឋានក្នុងថ្ងៃនោះឯង។ ការអធិស្ឋានជារឿយៗជាការអនុវត្តនដ៏រីករាយមួយ។ ទោះជាយ៉ាងនោះក្តី ប្រសិនជាមានការពិបាកនៅក្នុងការអធិស្ឋាន ហើយខ្ញុំក៏មិនបានដឹងពីបាបដែលមាននៅក្នុងជីវិតរបស់ខ្ញុំនោះ ការដើរទៅមកនៅពេលខ្ញុំអធិស្ឋាន ហើយពោលពាក្យលឺៗ នោះជាអ្វីដែលជួយដល់ខ្ញុំ។ មិនត្រឹមតែប៉ុណ្ណោះក៏ជួយខ្ញុំកុំឱ្យងោកងុយ ហើយជួយដល់ខ្ញុំអោយផ្ចង់អារម្មណ៍ នៅពេលដែលខ្ញុំកំពុងតែអធិស្ឋានបានដែរ។ នៅពេលអធិស្ឋាន ប្រសិនជាលោកអ្នកចាប់ផ្តើមស្រមើស្រមៃ សូមត្រឡប់ក្រោយទៅកន្លែងដែលលោកអ្នកបានបញ្ឈប់ការអធិស្ឋាននោះ ហើយចាប់ផ្តើមបន្តធិស្ឋានពីកន្លែងនោះមកវិញ។ ប្រសិនជាមានអ្វីរំខានដល់លោកអ្នក ដោយគំនិត និងដោយកិច្ចការដែលលោកអ្នកត្រូវធ្វើ នោះសូមសរសេរវាចុះនៅលើក្រដាសមួយសន្លឹក ដើម្បីទុកគិតអំពីកិច្ចការទាំងនោះនៅពេលក្រោយ ។

សូមផ្គូរផ្គងចម្លើយអោយបានត្រឹមត្រូវទៅនឹងខគម្ពីរនីមួយៗខាងក្រោមនេះ ។

ឧបសគ្គនៃការអធិស្ឋាន

| | |
|---|---|
| ម៉ាកុស ១១:២៥ | ការមិនជឿ |
| យ៉ាកុប ៤:៣ | ការមិនចេះអត់ទោស |
| យ៉ាកុប ១:៦,៧ | អំពើបាប |

| | |
|---|---|
| ទំនុកដំកើង ៦៦:១៨ | ការទូលសុំដោយបំណងខុសឆ្គង |

## ប្រភេទផ្សេងៗនៃការអធិស្ឋាន

ការដែលសំខាន់ ត្រូវចងចាំថាការអធិស្ឋានមិនគ្រាន់តែជាការទូលសុំប៉ុណ្ណោះនោះទេ។ ការអធិស្ឋាន ត្រូវមានការប្រកបយ៉ាងហោចណាស់ឲ្យបាន៤ ផ្នែកនេះដែរ គឺ ស.ល.អ.ទ

| | |
|---|---|
| សរសើរតម្កើង | សរសើរ និង ថ្វាយបង្គំ។ ទំនុកតម្កើង ៩៥:៦ |
| លន់តួបាប | ប្រែចិត្តពីបាបដែលបានដឹង។ ទំនុកដំកើង ៣២:៥ |
| អរព្រះគុណ | ការចេះអរព្រះគុណព្រះជាម្ចាស់។ ភីលីព ៤:៦ |
| ទូលអង្វរ | ការស្នើរសុំ។ ១ ធីម៉ូថេ ២:១ |

ប្រសិនជាលោកអ្នកមានឯកសិទ្ធិនៅក្នុងការធ្វើដំណើរជុំវិញពិភពលោកទៅកាន់ប្រទេសផ្សេងៗ ការដែលត្រូវយកចិត្តទុកដាក់នោះគឺការថែរក្សាសុខភាពឲ្យបានល្អ ។ លោកអ្នកត្រូវប្រយ័ត្នចំពោះរបបអាហារដែលត្រូវបរិភោគ និង អនាម័យ។ ដូចគ្នានេះដែរ សំរាប់ជីវិតអធិស្ឋានដែលមានផាសុខភាពក៏ត្រូវប្រកាន់ខ្ជាប់នូវលក្ខខណ្ឌមួយចំនួនដើម្បីទទួលបានចម្លើយដ៏ជាក់លាក់ ។

## គោលការណ៍សម្រាប់ជីវិតការអធិស្ឋានមួយដែលមានផាសុខភាព

### ១. យើងត្រូវតែអធិស្ឋានស្របតាមបំណងព្រះហឫទ័យព្រះជាម្ចាស់

សូមអាន *យ៉ាកុប ៤:៣*
យើងត្រូវតែពិនិត្យមើលបញ្ញាចិត្តរបស់យើង ដើម្បីកំណត់ពីការអធិស្ឋានរបស់យើងតើចេញមកពីបំណងប្រាថ្នាដែលល្អ ឬចេញពីគំនិតអាត្មានិយម។



គ្មានឪពុកណាព្រមឱ្យអ្វីៗគ្រប់យ៉ាងទៅតាមអ្វីដែលកូនតូចទទូចសុំនោះទេ ទោះបី ជាគាត់ខំអង្វរកយ៉ាងណាក៏ដោយ ។ ឧទាហរណ៍៖ សុំកាំបិត ឬ ឈើគូស ជាដើម។ ការអានព្រះគម្ពីរពេលខ្លះក៏អាចជួយបញ្ជាក់ពីបញ្ញាចិត្តរបស់យើងបានដែរ។ ទោះជាយ៉ាងនោះក្តី សូមកុំមានការយឺតយ៉ាវនៅក្នុងការទូលថ្វាយសំណូមពររបស់លោកអ្នកទៅកាន់ព្រះជាម្ចាស់នោះឡើយ ។

### ២. យើងត្រូវអត់ទោសដល់អ្នកដទៃចំពោះកំហុសដែលពួកគេបានធ្វើ

សូមអាន *ម៉ាកុស ១១:២៥*
មានគ្រិស្តបរិស័ទជាច្រើនបានបិទបាំងការអាក់អន់ចិត្ត នៅក្នុងជីវិតរបស់ពួកគាត់ចំពោះអ្នកដទៃ ។ ការអាក់អន់ចិត្តនេះហើយដែលជាទូទៅបានឆក់យើងចេញពីព្រះវត្តមានរបស់ព្រះជាម្ចាស់ ។

### ៣. យើងត្រូវតែនៅជាប់នឹងព្រះគ្រិស្ត

សូមអាន *យ៉ូហាន ១៥:៧*
នៅពេលដែលមែកឈើមួយនៅជាប់នឹងដើមរបស់វា មែកនោះនឹងនៅតែមានសុខភាពល្អ។ ដូចគ្នាទៅនឹងគ្រិស្តបរិស័ទសម្រាប់ការបន្តរស់រាននៅក្នុងជីវិតខាងព្រលឹងវិញ្ញាណ គឺដោយការរៀនស្តាប់បង្គាប់តាមសេចក្តីបង្រៀនរបស់ព្រះគ្រិស្ត ព្រមទាំងបើកចិត្ត ចំពោះអ្វីដែលទ្រង់ចង់មានព្រះបន្ទូលមកក្នុងជម្រៅចិត្តរបស់យើង។ ហើយជួនកាលអាចជាការដែលគ្រាន់តែនៅស្ងៀម ហើយចាំស្តាប់នូវអ្វីដែលទ្រង់សព្វព្រះហរទ័យមានព្រះបន្ទូលតែប៉ុណ្ណោះ ។

### ៤. យើងត្រូវតែអធិស្ឋាន ដោយជំនឿ

*សូមអាន ម៉ាកុស ១១:២៤ ។*

ប្រសិនបើលោកអ្នក ប្រាកដច្បាស់នៅក្នុងការរអធិស្ឋានរបស់លោកអ្នកថាមានបញ្ញាចិត្តត្រឹមត្រូវ នោះត្រូវអធិស្ឋានដោយមានទំនុកចិត្តដូចដែលលោកអ្នក កំពុងតែឈរនៅចំពោះបល្ល័ង្ករបស់ស្តេច ដែលមានអំណាចនៅក្នុងការឆ្លើយតបយ៉ាងនោះដែរ។

*សូមអាន ម៉ាថាយ ១៨:១៩*

មេទ័ពរ៉ូម៉ាំងដែលមានអ្នកបំរើម្នាក់ឈឺបានមករកព្រះយេស៊ូ ដោយទូលសុំឱ្យព្រះអង្គប្រោសគាត់ឱ្យជា។ មនុស្សភាគច្រើននៅសម័យនោះ ពួកគេបានទូលសុំឲ្យព្រះយេស៊ូមករកអ្នកជម្ងឺ ប៉ុន្តែសម្រាប់គាត់វិញគឺផ្ទុយស្រឡះពីគេ។ លោកទូលព្រះអង្គថា៖ *«សូមលោកមានប្រសាសន៍តែមួយម៉ាត់ប៉ុណ្ណោះ អ្នកបម្រើរបស់ខ្ញុំប្របាទនឹងជាសះស្បើយមិនខាន” ម៉ាថាយ ៨:៨* ។ នោះហើយគឺជាជំនឿដែលជាការជឿជាក់ថាព្រះជាម្ចាស់នឹងឆ្លើយតបពិតមែន។

**៥. យើងត្រូវតែអធិស្ឋាន នៅក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត**

*សូមអានយ៉ូហាន ១៦:២៤*

នៅក្នុងព្រះគម្ពីរ ឈ្មោះរបស់មនុស្សម្នាក់គឺតំណាងឲ្យលក្ខណ:សម្បត្តិរបស់បុគ្គលនោះតែម្តង។ ដោយហេតុនោះហើយទើបនៅពេលអធិស្ឋាននៅក្នុងព្រះនាមព្រះយេស៊ូ យើងអធិស្ឋានសម្រាប់ ព្រះកិត្តិយសរបស់ព្រះអង្គ មិនមែនដោយនៅយើងផ្ទាល់នោះទេ។ វាជាការត្រឹមត្រូវដែលរួមបញ្ចូល «ក្នុងព្រះនាមព្រះយេស៊ូ» នៅក្នុងការអធិស្ឋានរបស់យើង ។

# សេចក្តីសន្និដ្ឋាន

មានជំនួយផ្សេងទៀត ក៏អាចជួយបានផងដែរ ដើម្បីរៀបចំចិត្តរបស់លោកអ្នក សម្រាប់ការអធិស្ឋាន។ ប្រយោជន៍នៃការអានបទគម្ពីរទំនុកតម្កើង ដែលបង្ហាញពីគំនិតរបស់លោកអ្នក នោះលោកអ្នកក៏អាចយកការអធិស្ឋាននោះមកធ្វើជាសេចក្តីអធិស្ឋានផ្ទាល់បានដែរ។ ការសរសេរចេញនូវការអធិស្ឋានក៏ជារបៀបមួយទៀតនៅក្នុងការបញ្ចេញគំនិតឲ្យបានកាន់តែច្រើន ពីអ្វីដែលលោកអ្នកចង់អធិស្ឋាន។ ចុងក្រោយបង្អស់ ត្រូវរៀនពីការនៅស្ងៀម ហើយទន្ទឹងចាំស្តាប់នូវអ្វីដែលព្រះអង្គសព្វព្រះហរទ័យមានបន្ទូលមកកាន់លោកអ្នក ។

សូមសរសើរតម្កើងព្រះជាម្ចាស់ សម្រាប់ចម្លើយចំពោះការអធិស្ឋាន ។ ទាំងបុគ្គល ប្រជាជាតិ និងរដ្ឋាភិបាល ដែលទទួលបានការផ្លាស់ប្រែតាមរយ:ការអធិស្ឋាននេះ។ ប៉ុន្តែទោះជាការអធិស្ឋានជាច្រើនរបស់យើងត្រូវបានឆ្លើយតបភ្លាមៗក៏ដោយ



ក៏នៅតែមានការអធិស្ឋានខ្លះត្រូវការពេលវេលាយ៉ាងយូរមុននឹងមានការឆ្លើយតបមកដល់។ ប្រហែលជាយើងមិនបានទទួលចំលើយចំពោះពាក្យអធិស្ឋានពេញមួយជីវិតរបស់យើង ឬ តាមរបៀបដែលយើងរំពឹងទុកក៏ថាបាន។ ទីសម្គាល់ដ៏លាក់កំបាំង បានបង្ហាញឲ្យខ្ញុំដឹងថាព្រះជាម្ចាស់ឆ្លើយតបការអធិស្ឋានក្នុងពេលដ៏ត្រឹមត្រូវ និងតាមរបៀបមួយដ៏ត្រឹមត្រូវដែរ។ ស្ថានភាពខ្លះទៀតទាល់តែពេលដែលយើងទៅដល់ស្ថានសួគ៌ ទើបយើងអាចយល់បាន។

ភាពជោគជ័យដែលស្ថិតស្ថេរនៃជីវិតគ្រិស្តបរិស័ទ និងការបម្រើ អាចធ្វើការវាស់វែងបាន ទៅតាមប្រសិទ្ធភាពនៃជីវិតអធិស្ឋានរបស់លោកអ្នក ដូច្នោះហើយ សូមរក្សាការអធិស្ឋានទុកជាអាទិភាពទីមួយ ។ ហើយទោះបីជាពេលដែលលោកអ្នកខកខានក៏ដោយ ក៏លោកអ្នកនៅតែអាចវិលមករកទម្លាប់នេះវិញបានដែរ។

*« នោះបើប្រជារាស្ត្ររបស់យើង ដែលបានហៅតាមឈ្មោះយើង បន្ទាបខ្លួន*

*ហើយអធិស្ឋានរកមុខយើង ព្រមទាំងងាកបែរចេញពីផ្លូវអាក្រក់របស់គេ នោះយើងនឹងស្តាប់ពីលើស្ថានសួគ៌ ហើយអត់ទោសអំពើបាបរបស់គេ ទាំងមើលស្រុកគេឲ្យជាផង។»*
*២ របាក្សត្រ ៧:១៤*